**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ : ៦៦ ប្រក.បក

# ប្រកាស
## ស្តីពី
## ការលុបឈ្មោះមន្ត្រីរាជការ

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ១១០/១៩ ក.ស.វ. ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌
- យោងលិខិតលេខ០៨៦/១៩ វសស ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩ របស់វេទិកាសម្ព័ន្ធសង្គមស៊ីវិល

## សម្រេច

**ប្រការ១.-**

លុបឈ្មោះមន្ត្រីរាជការចំនួន ០៤រូប ចេញពីក្របខណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដោយមូលហេតុសាមីខ្លួនអវត្តមានពីការងារ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១. លោក | **ទឹម បុរី** | មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ |
| ២. លោក | **ជៀម ស្រ៊ុន** | មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ |
| ៣. លោក | **គីម សៅឌី** | មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃវេទិកាសម្ព័ន្ធសង្គមស៊ីវិល |

៤. លោកស្រី **ហួន សុខធេវី** មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន។

**ប្រការ២..**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ប្រធានវេទិកាសម្ព័ន្ធសង្គមស៊ីវិល អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៣កើត ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ តុលា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល:**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ